**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៩៦ សហវ.ប្រក.ពន្ធ

# ប្រកាស
## ស្តីពី
## ការបែងចែកថ្នាក់រង្វាន់ពីការត្រួតពិនិត្យពន្ធ លើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញប្រកាសលេខ ០០៤ ប្រក/សហវ/ពដ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០០១ ស្តីពីការផ្តល់រង្វាន់ជូនអង្គភាពពន្ធដារ

- បានឃើញប្រកាសលេខ ២៨៧ សហវ/ពដ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបែងចែកប្រាក់រង្វាន់របស់អង្គភាពពន្ធដារ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០០៨ ។

**សំរេច :**

**ប្រការ ១ :** ក្នុងរយៈពេលត្រួតពិនិត្យជារៀងរាល់ឆ្នាំ ប្រាក់ផាកពិន័យលើពន្ធមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទទួលបានក្នុងការចូលរួមកិច្ចប្រតិបត្តិការត្រួតពិនិត្យ ដោយមានសហការរវាងមន្ត្រីពន្ធដារ និងមន្ត្រីមានសមត្ថកិច្ច ត្រូវអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់តាមសមាមាត្រ ដូចតទៅ :

១- ៥០% (ហាសិបភាគរយ) ត្រូវបង់ចូលថវិកាជាតិ ។

២- ៥០% (ហាសិបភាគរយ) ត្រូវបានអនុញ្ញាតឱ្យបែងចែកជាប្រាក់រង្វាន់ ដូចតទៅ :

- ១៥% (ដប់ប្រាំភាគរយ) បង់ចូលអគ្គនាយកដ្ឋានពន្ធដារ
- ៣៥% (សាមសិបប្រាំភាគរយ) សំរាប់បែងចែកដូចខាងក្រោម : (១០០% នៃ ៣៥%)
  - \+ ៦០% នៃប្រាក់រង្វាន់ សំរាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ។
  - \+ ២០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាខាពន្ធដារខេត្ត ឬសាខាពន្ធដារខណ្ឌ នៃរាជធានីភ្នំពេញ ។
  - \+ ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខេត្ត ឬរាជធានីភ្នំពេញ ។
  - \+ ១០% នៃប្រាក់រង្វាន់ សំរាប់បេឡាសមូហភាពរបស់សាលាខណ្ឌ-ស្រុក-ក្រុង ។

**ប្រការ ២ :** អនុញ្ញាតឱ្យសាខាពន្ធដារខេត្ត ឬសាខាពន្ធដារខណ្ឌ នៃរាជធានីភ្នំពេញ ដកប្រាក់រង្វាន់ពីការផាកពិន័យពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំនីមួយៗភ្លាម សំរាប់បែងចែកជូនសមាជិកក្រុមត្រួតពិនិត្យ និងអង្គភាពតាមសមាមាត្រដូចបានចែងក្នុងប្រការ១ខាងលើ ហើយត្រូវធ្វើរបាយការណ៍បូកសរុបពីស្ថានភាពចំណូល និងចំណាយបេឡាប្រាក់ផាកពិន័យនេះជូនអគ្គនាយកដ្ឋានពន្ធដារ ដើម្បីត្រួតពិនិត្យ និងសំរាប់ទូទាត់ជាក្រោយ ដូចមានគំរូឧបសម្ព័ន្ធភ្ជាប់មកជាមួយ ។

**ប្រការ ៣ :** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥

**គាត ឈន់**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជារបាយការណ៍"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត រាជធានីភ្នំពេញ-ក្រុង-ខណ្ឌ-ស្រុក "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសហវ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត សាខាពន្ធដារខណ្ឌ នៃរាជធានីភ្នំពេញ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ